# របាយការណ៍ទិន្នន័យលើកទី៦នៃកម្មវិធីតម្លាភាពរបស់គម្រោង
# រោងចក្រកាន់តែប្រសើរនៅកម្ពុជា

**ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦**

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាបន្តពង្រីកបន្ថែម កម្មវិធីការផ្សព្វផ្សាយជាសាធារណៈនូវកម្រិត នៃការអនុលោមតាមច្បាប់របស់រោងចក្រ។ ទិន្នន័យនៅក្នុងរបាយការណ៍ចុងក្រោយនេះ បង្ហាញអោយឃើញថា ការផ្សព្វផ្សាយជាសារណៈ គឺជាចលករនៃការផ្លាស់ប្តូរមួយដ៏សំខាន់។ បើធ្វើការប្រៀបធៀបរវាងទិន្នន័យក្នុងរបាយការណ៍មុន និងក្រោយពេលកម្មវិធីតម្លាភាពចាប់ផ្តើម ទិន្នន័យដែលបានប្រមូលពីរោងចក្រនៅក្នុងរបាយការណ៍លើកទី៦នេះ បានបង្ហាញពីការកើនឡើងរហូតដល់៥៧% នៃចំនួនរោងចក្រដែលបានអនុលោមតាមច្បាប់ លើបញ្ហាចំបងៗទាំង២១ចំនុច។ ការប្រៀបធៀបទិន្នន័យនេះក៏បង្ហាញពីការផ្លាស់ប្តូរជាវិជ្ជមាន លើចំនុចជាក់លាក់មួយចំនួននៃបញ្ហាចំបងៗ ដែលការផ្លាស់ប្តូរនេះមានចន្លោះ ពីរ ៧% ទៅ១៤%។

តាមរយៈការផ្សាយរបាយការណ៍ទិន្នន័យលើកទី៦ នៃការអនុលោមច្បាប់របស់រោងចក្រ កម្មវិធីតម្លាភាពលើប្រព័ន្ធអ៊ីនធើណិតរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាឥឡូវនេះ ផ្ទុកពត៌មានអំពីរបាយការណ៍នៃការវាយតម្លៃលក្ខណការងារចំនួន៦៤៩ ពីរោងចក្រចំនួន ៤១៩ ដែលស្មើនឹង៧៤% នៃចំនួនរោងចក្រកាត់ដេរដែលមានលិខិតអនុញ្ញាតនាំចេញក្នុងប្រទេសកម្ពុជា។ ខាងក្រោមជាការសង្ខេបតាមផ្នែកនីមួយៗ ដែលរួមមានការអនុវត្តច្បាប់នៅមានកម្រិតទាប បញ្ហាចំបងៗ និងការអនុវត្តច្បាប់របស់សហជីព។

**ការអនុវត្តច្បាប់នៅមានកម្រិតទាប៖** រោងចក្រ ដែលការគោរពច្បាប់មានកម្រិតទាបបំផុត ត្រូវបានដាក់បញ្ចូលក្នុងក្រុមដែលការអនុវត្តច្បាប់មានកម្រិតទាប។[១] ក្នុងអំឡុងពេលនៃរបាយការណ៍ថ្មីនេះ រោងចក្រចំនួន៦ ត្រូវបានដាក

បញ្ចូលក្នុងក្រុមនេះ។ សរុបមក ក្នុងចំណោមរោងចក្រចំនួន៤១៩ មានរោងចក្រ ចំនួន២០ ឬ ស្មើរនិង ៤,៧% នៃរោងចក្រទាំងអស់ក្នុងកម្មវិធីតម្លាភាព ស្ថិតក្នុងបញ្ជីរោងចក្រដែលការអនុវត្តច្បាប់នៅមានកម្រិតទាប។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ធ្វើការចែករំលែកព័ត៌មាន ជាមួយរាជរដ្ឋាភិបាលកម្ពុជា អំពីរោងចក្រដែលមានការអនុវត្តច្បាប់នៅមានកម្រិតទាប។ មន្ត្រីរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ជាមួយមន្ត្រីតំណាងមកពីក្រសួងពាណិជ្ជកម្ម និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើកិច្ចប្រជុំរួមគ្នាចំនួនពាដង ទៅកាន់រោងចក្រ ដែលការអនុវត្តច្បាប់នៅមានកម្រិតទាបទាំងនោះ។ កិច្ចប្រជុំទាំងនេះ គឺជាធាតុមួយដ៏សំខាន់ និងឆ្លុះបញ្ចាំងពីកិច្ចសហប្រតិបត្តិការ រវាងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងចែករំលែកព័ត៌មានពីដំណើការនៃការឃ្លាំមើល និងជួយសម្រួលដល់សកម្មភាពតាមដាន តាមរយៈក្រសួងដោយផ្អែកលើតួនាទីរបស់ខ្លួននីមួយៗ។

ព័ត៌មានបន្ថែមអំពី រោងចក្រដែលការអនុវត្តច្បាប់នៅមានកម្រិតទាប អាចរកបានតាមរយៈ
http://betterfactories.org/transparency/en/issues/view/low_compliance។

**បញ្ហាចំបងៗ៖** ការផ្សព្វផ្សាយជាសាធារណៈ នៅតែបន្តជាចលករនៃការផ្លាស់ប្តូរមួយដ៏សំខាន់។ ក្នុងរបាយការណ៍ថ្មីនេះ មានរបាយការណ៍វាយតម្លៃលក្ខខណ្ឌការងាររោងចក្រចំនួន១៤៧ ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបញ្ហាចំបងៗ។ ក្នុងនោះមាន រោងចក្រចំនួន ៦៦ (ស្មើនឹង៤៥%) បានគោរពពេញលេញលើប្រភេទបញ្ហាចំបងៗទាំង២១ចំនុច និងមានរោងចក្រចំនួន៨១ (ស្មើនឹង៥៥%) មិនបានអនុវត្តតាមច្បាប់លើបញ្ហាមួយចំនុច ឬច្រើនជាងនេះ។ សរុប ចំនួនករណីនៃការមិនបានអនុវត្តតាមច្បាប់របស់រោងចក្រទាំងនេះ មាន១៦០ករណី។

មុនពេលរបាយការណ៍ត្រូវបានផ្សាយ មានតែរោងចក្រចំនួន៤២ (ឬ២៩%) ដែលបានគោរពពេញលេញ លើច្បាប់ជាមូលដ្ឋាន ក្នុងប្រភេទបញ្ហាចំបងៗទាំង២១ចំនុច ចំណែកឯរោងចក្រចំនួន ១០៥ ទៀត (ស្មើនឹង៧១%) មិនបានបំពេញតម្រូវការច្បាប់ជាមូលដ្ឋានចំនួន២១ចំនុច យ៉ាងហោចណាស់១ចំនុច។ សរុបមក ក្រុមនេះមានការមិនបានអនុវត្តតាមច្បាប់ រហូតដល់ ២២៤ករណី ជាមួយនឹងបញ្ហាចំបងៗ។




ក្រាប១៖ របាយការណ៍កម្មវិធីលើកទី៦ រោងចក្រដែលបំពេញតម្រូវការច្បាប់លើបញ្ហាចំបងៗ មុន និងក្រោយ កម្មវីធីតម្លាភាព។

បើធ្វើការប្រៀបធៀបរវាងទិន្នន័យមុន និងក្រោយពេលកម្មវិធីតម្លាភាពចាប់ផ្តើម ទិន្នន័យ ដែលបានប្រមូលពីរោងចក្រដែលត្រូវបានដាក់បញ្ចូលនៅក្នុងរបាយការណ៍លើកទី៦នេះ បានបង្ហាញពីការកើនឡើងរហូតដល់៥៧% នៃចំនួនរោងចក្រដែលបានអនុលោមតាម ច្បាប់ លើបញ្ហាចំបងៗទាំង២១ចំនុច ចំណែកឯករណីដែលមិនបានអនុលោមបានពេញលេញលើបញ្ហាទាំង២១ចំនុចបានថយចុះ ប្រហែល ៣៤%។

ទិន្នន័យបន្តបង្ហាញដែរថា ការធ្វើអោយប្រសើរឡើងលើការអនុវត្តច្បាប់មួយចំនួន គឺជាការរួមចំណែករបស់កម្មវិធីតម្លាភាពស្តីពីការដាក់ចេញ រោងចក្រដែលស្ថិតនៅក្រុមបញ្ហាចំបងៗទាំង២១ចំនុច និងក្រុមរោងចក្រដែលមានការអនុលោមច្បាប់នៅមានកម្រិតទាប។ក្រោយពីគម្រោងតម្លាភាពបានចាប់ផ្តើម ការផ្លាស់ប្តូរជាវិជ្ជមានលើបញ្ហាសំខាន់ៗមួយចំនួនបានកើនឡើង។ ក្រាបខាងក្រោមបង្ហាញពីលទ្ធផល របាយការណ៍វាយតម្លៃចុងក្រោយរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាលើរោងចក្រចំនួន៤១៩ នៅក្នុងទិន្នន័យរបាយការណ៍សាធារណៈ ហើយធ្វើការប្រៀបធៀបទិន្នន័យនេះជាមួយនឹងទិន្នន័យ របាយការណ៍វាយតម្លៃចុងក្រោយ មុនពេលការចាប់ផ្តើមរបស់កម្មវិធីតម្លាភាពនៅក្នុងរោងចក្រដូចគ្នា ដោយផ្តោតលើបញ្ហានានាដែលមានការកើនឡើងខ្ពស់បំផុត ក្នុងកម្រិតអនុលោមតាមច្បាប់៖




ក្រាប២៖ ការផ្លាស់ជាវិជ្ជមានគួរអោយកត់សម្គាល់ក្រោយពេលកម្មវិធីតម្លាភាពចាប់ផ្តើម[២]

**<u>ការអនុវត្តច្បាប់របស់សហជីព៖</u>** ស្ថានភាពនៃតម្រូវការផ្នែកច្បាប់របស់សហជីពក្នុងការធ្វើកូដកម្មក៏ត្រូវបានបង្ហាញជាសាធារណៈផងដែរ។ គ្រប់កូដកម្មទាំង៣៤ ដេលត្រូវបានធ្វើឡើងនៅក្នុងរោងចក្រ ដែលត្រូវបានដាក់បញ្ចូលនៅក្នុងទិន្នន័យតម្លាភាពលើកទី៦នេះ ពុំមានកូដកម្មណាមួយដែលបានធ្វើឡើង គោរពទៅតាមនីតិវិធីយ៉ាងហោចមួយចំនុចនៃតម្រូវការរបស់ច្បាប់ពេញលេញនោះទេ។ ពត៏មានលំអិតអំពីកូដកម្មទាំង នេះក៏ដូចជាសហពន្ធ័សហជីព និង សហជីពតាមរោងចក្រនីមួយៗ ដែលពាក់ព័ន្ធនឹង កូដកម្មអាចរកតាមរយៈ http://betterfactories.org/transparency/en/factory_strikes/view.។

សម្រាប់ពត៏មានបន្ថែមទាក់ទងនឹងកម្មវិធីតម្លាភាពរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា អាចរកបានលើគេហទំព័រ www.betterfactories.org/transparency។

---

[១]រោងចក្រដែលមានកម្រិតនៃការគោរពច្បាប់ទាបបំផុត គឺជារោងចក្រដែលមានកម្រិតពិន្ទុ ទាបជាង មធ្យម ដក២ដងនៃគម្លាតពីមធ្យម ក្នុងការអនុលោមលើចំនុចទាំង៥២ ក្នុងចំណោមរោងចក្រទាំងអស់ដែលត្រូវបានត្រួតពិនិត្យចាប់ពីបីដង ដោយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា។ សម្រាប់ពត៏មានបន្ថែមពី រោងចក្រដែលមានកម្រិត

នៃការគោរពច្បាប់ទាប អាចរកបានតាមរយៈ
http://betterfactories.org/transparency/uploads/22320-ci_lw_details_english.pdf

[២] ក្រាបលេខ២ខាងលើផ្អែកលើទិន្នន័យដកស្រង់ពីរបាយការណ៍ចំបងៗ និងបញ្ហាទាំង៥២ ដែលប្រើប្រាស់សម្រាប់គណនារោងចក្រដែលមានការគោរពច្បាប់នៅមានកម្រិតទាប។